**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៣

លេខ ២០/២០០៣ កបធ

**សូមក្រាបថ្វាយបង្គំទូលថ្វាយ**

**ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ**

**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

សូមទ្រង់ព្រះមេត្តាជ្រាប ។

**កម្មវត្ថុ** : សេចក្តីថ្វាយយោបល់ចំពោះចំណុចផ្នែកច្បាប់មួយចំនួន

**យោង** : ព្រះរាជសារ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៣

ទូលព្រះបង្គំយើងខ្ញុំ ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញក្រោយពីបានទទួលព្រះរាជសារ ដូចមានយោងខាងលើ បានរួមប្រជុំក្រុមប្រឹក្សាធម្មនុញ្ញនៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៣ ហើយសូមព្រះរាជានុញ្ញាតថ្វាយយោបល់ថា ក្រុមប្រឹក្សាធម្មនុញ្ញពុំមានសមត្ថកិច្ចធ្វើការវិភាគបកស្រាយទិដ្ឋភាពនយោបាយដែលមាន លើកឡើងក្នុងព្រះសារលិខិតរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានគណបក្សហ៊្វុនស៊ិនប៊ិច ទេប៉ុន្តែសូមព្រះរាជានុញ្ញាតថ្វាយយោបល់បំភ្លឺចំពោះចំណុចផ្នែកច្បាប់មួយចំនួនដូចតទៅ:

**១~ សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ**

ការបកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ជាផ្លូវការ ជាសមត្ថកិច្ចផ្តាច់មុខរបស់ក្រុមប្រឹក្សាធម្មនុញ្ញ( មាត្រា១៣៦ ថ្មី និង មាត្រា ១៤២ ថ្មី នៃរដ្ឋធម្មនុញ្ញ មាត្រា ១ មាត្រា១៥ និង មាត្រា២៣ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ) ។

ចម្លើយរបស់ក្រុមប្រឹក្សាធម្មនុញ្ញចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៣ ទៅនឹងព្រះរាជសំណើសួរយោបល់ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ នោះ គឺធ្វើឡើងនៅក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចនេះ ។

តាមយុត្តិសាស្ត្រខ្ជាប់ខ្ជួនរបស់ក្រុមប្រឹក្សាធម្មនុញ្ញតាំងពីឆ្នាំ ១៩៩៨ មក ឥស្សរជន ដែលមានចែងក្នុង មាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញអាចសុំអោយក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់បាន ។

ក្នុងចំណោមឥស្សរជននោះ គេរាប់ព្រះមហាក្សត្រមុនគេ ។

ក្នុងព្រះឋានៈជាប្រធានរដ្ឋសភា សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ**ក៏ធ្លាប់បានសុំជាញយឱ្យ ក្រុមប្រឹក្សាធម្មនុញ្ញ និង ច្បាប់ ក្រៅពីការសុំឱ្យត្រួតពិនិត្យធម្មនុញ្ញភាពដែរ ។

**២~ មាត្រា ៨២ នៃរដ្ឋធម្មនុញ្ញ**

ក្នុងចម្លើយរបស់ក្រុមប្រឹក្សាធម្មនុញ្ញនោះ ក្រុមប្រឹក្សាធម្មនុញ្ញបានលើកមាត្រា ៨២ នៃរដ្ឋធម្មនុញ្ញយកមកនិយាយ ដើម្បីបញ្ជាក់ចំណុចនៃការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

ប៉ុន្តែចំពោះបញ្ហាព្រះរាជវត្តមាន ក្រុមប្រឹក្សាធម្មនុញ្ញមិនបានបកស្រាយថា " ព្រះករុណា *ត្រូវតែ* ស្តេចយាងទៅបើករដ្ឋសភានៃនីតិកាលទី៣ "ទេ ។ ព្រះករុណាព្រះអង្គទ្រង់បានសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញផ្តល់យោបល់ ដ៏ខ្លីថា " *តើខ្ញុំ មហាក្សត្រ នរោត្តម សីហនុ ត្រូវទៅ បើករដ្ឋសភានៃនីតិកាលទី៣ ឬ មិនត្រូវទៅ* " ហើយជាចម្លើយដ៏ខ្លី ក្រុមប្រឹក្សាធម្មនុញ្ញបានឆ្លើយថា "***ត្រូវទៅ***" ដូច្នេះគឺមិនមែន "***ត្រូវតែទៅ***" ទេ ។

ពាក្យថា "***ត្រូវទៅ***" គ្រាន់តែជាពាក្យឆ្លើយខ្លីឱ្យចំសំនួរតែប៉ុណ្ណោះគឺគ្មានលក្ខណៈបង្ខំទេ ។

**៣_បញ្ហាចំនួនតំណាងរាស្ត្រក្នុងសម័យប្រជុំដំបូង**

ក្រុមប្រឹក្សាធម្មនុញ្ញមិនបានលើកចំណុចនេះឡើងក្នុងចម្លើយរបស់ខ្លួន ពីព្រោះដើម្បីកុំឱ្យខុសពីព្រះរាជសំនួរ និង ព្រះរាជសំណើដែលសុំឱ្យឆ្លើយខ្លីថា "***ត្រូវទៅ***" ឬ "***មិនត្រូវទៅ***" ។

ប៉ុន្តែក្នុងពេលប្រជុំនោះ ក្រុមប្រឹក្សាធម្មនុញ្ញក៏មានបានជជែកគ្នាដែរ អំពីបញ្ហានេះ ។

ក្រុមប្រឹក្សាធម្មនុញ្ញសូមបញ្ជាក់បំភ្លឺម្តងទៀតថា តំណាងរាស្ត្រ ១២០ រូប យ៉ាងតិចគឺ ជាល័ក្ខខ័ណ្ឌចាំបាច់ដែលការរៀបចំការបោះឆ្នោតត្រូវបំពេញដើម្បីបង្កើតរដ្ឋសភាមួយបាន សំរាប់នីតិកាលនីមួយៗ ។

កាលណាបើលទ្ធផលផ្លូវការដែលអស់មានតវ៉ាកើត បានចេញចំនួនតំណាងរាស្ត្រស្មើ ឬ លើស ១២០ រូបហើយ គឺរដ្ឋសភាកើតរួចហើយ ។តំណាក់កាលផ្សេងៗទៀតដែលរដ្ឋសភាថ្មីត្រូវបំពេញ ដើម្បីអាចទៅចូលកាន់តំណែង ត្រូវអនុវត្តតាមនីតិវិធីដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា ។

មាត្រា ៨២ នៃរដ្ឋធម្មនុញ្ញដែលជាផ្នែកមួយនៃនីតិវិធីនេះ ពុំមានចែងតម្រូវឱ្យមានចំនួនតំណាងរាស្ត្រ ១២០ រូប យ៉ាងតិចទេ ក្នុងពេលបើកសម័យប្រជុំដំបូង ហើយប្រការ ៥ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភាក៏ឥតមានចែងដែរ ប៉ុន្តែបានចែងចំនួនតំណាងរាស្ត្រដែលត្រូវមាន នៅក្រោយពេលបើកនេះ ។

ប្រការ ៥ និយាយប៉ុណ្ណោះមានន័យច្បាស់លាស់ គ្រប់គ្រាន់ណាស់ទៅហើយ ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៥៤.០០៥.២០០៣ កបធ.ច ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០០៣ ដែលសម្តេចក្រុមព្រះបានលើកឡើងនោះ មានន័យដូចខាងលើនេះ គឺថាមិនដូចព្រះអង្គបកស្រាយឡើយ ។

**៤_ទីកន្លែងប្រជុំរដ្ឋសភា**

លុះត្រាតែមានកាលៈទេសៈតម្រូវទើបសម័យប្រជុំរដ្ឋសភាអាចធ្វើនៅកន្លែងផ្សេងពីសាលប្រជុំរបស់រដ្ឋសភា ។ បើពុំដូច្នោះទេ ការប្រជុំណាក៏ដោយរបស់រដ្ឋសភាត្រូវទុកជាខុសច្បាប់ហើយជាអសារសូន្យពេញលក្ខណៈ ( មាត្រា ៨៥ នៃរដ្ឋធម្មនុញ្ញ ) ។

**៥_ ការធ្វើសច្ចាប្រណិធាន**

តាមខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី ៥ នៃរដ្ឋធម្មនុញ្ញ សច្ចាប្រណិធានត្រូវធ្វើនៅ "ចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ ព្រះភ័ក្ត្រសម្តេចព្រះសង្ឃរាជ និង ទេវតារក្សាស្វេតច្ឆ័ត្រ " គឺបានន័យថានៅក្នុងព្រះបរមរាជវាំង បើព្រះមហាក្សត្រ ព្រះអង្គទ្រង់គង់នៅទីនោះ ។

**៦_ ព្រះរាជតំណាង**

ព្រះមហាក្សត្រមានព្រះរាជបុព្វសិទ្ធិពេញទី ក្នុងការចាត់តាំងព្រះរាជតំណាង ។

គោលការណ៍ នេះមិនអាចត្រូវគេរំលោភបានឡើយ ។

វិសមភាព ជាបញ្ហាដែលពាក់ព័ន្ធនឹងមុខងារ ។ការទទួលព្រះរាជបញ្ជាដើម្បីឱ្យទៅបើកសម័យប្រជុំ ក្នុងឋានៈជា

ព្រះរាជតំណាង មិនមែនជាមុខងារទេ គឺគ្រាន់តែជាបេសកម្មចំពោះមុខមួយគ្រាប៉ុណ្ណោះ ។
នេះជាទិដ្ឋភាពច្បាប់សុទ្ធសាធ ។
ក្រុមប្រឹក្សាធម្មនុញ្ញមិនមានសមត្ថកិច្ចធ្វើការវិភាគបកស្រាយទិដ្ឋភាពនយោបាយឡើយ ។

សូមក្រាបបង្គំទូលថ្វាយ ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ជាទីបំផុត ។
សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**
**ប្រធាន**

**ប៊ិន ឈិន**